# គ្រាប់ពូជ និងគម្រោងគ្រាប់ពូជ
# Seeds and Seed Projects

**សេចក្តីសង្ខេប:**

ព្រះជាម្ចាស់ចម្រើនដល់កិច្ចការ (គ្រាប់ពូជ) តូចៗចេញពីការស្តាប់បង្គាប់ដើម្បីពង្រីកនគររបស់ព្រះអង្គ។ គម្រោងគ្រាប់ពូជគឺជាឧបករណ៍មួយដ៏សាមញ្ញ និងដ៏មានប្រសិទ្ធភាព ដែលជួយឱ្យពួកជំនុំមូលដ្ឋានអាចបង្ហាញចេញនគររបស់ព្រះជាម្ចាស់នៅក្នុងសហគមន៍របស់ពួកគេ តាមរយៈការបម្រើដោយសេចក្តីស្រលាញ់។

**គំនិតចម្បង:**

១. រឿងប្រៀបធៀបនៅក្នុងព្រះគម្ពីរអំពីគ្រាប់ពូជ ផ្តល់គោលការណ៍សំខាន់ៗសម្រាប់ព័ន្ធកិច្ច។

២. គម្រោងគ្រាប់ពូជគឺជាគម្រោងតូចៗដែលពួកជំនុំមូលដ្ឋានធ្វើ ដោយប្រើធនធានផ្ទាល់ខ្លួន និងដោយមានគោលបំណងបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់មនុស្សដែលនៅក្រៅពួកជំនុំ។

៣. ផលប្រយោជន៍ពីគម្រោងគ្រាប់ពូជរួមមានមនុស្សត្រូវបានទាញមកឯព្រះគ្រីស្ទ សេចក្តីត្រូវការយ៉ាងច្រើននៅក្នុងសហគមន៍ត្រូវបានបំពេញតាមរយៈសេចក្តីស្រលាញ់របស់ព្រះគ្រីស្ទ សេរីភាពរួចផុតពីការពឹងផ្អែកលើធនធានខាងក្រៅ និងទទួលបានបទពិសោធន៍សម្រាប់កិច្ចខិតខំប្រឹងប្រែងកាន់តែធំនៅពេលអនាគត។

៤. គម្រោងគ្រាប់ពូជមានលក្ខណៈទូទៅដប់។

៥. គម្រោងគ្រាប់ពូជមានប្រសិទ្ធភាពបំផុតសម្រាប់នាំមកនូវការបំផ្លាស់បំប្រែ (ប្រសិទ្ធភាពរយៈពេលវែង) នៅពេលដែលគម្រោងទាំងនោះផ្តោតលើមនុស្សដដែល ធ្វើឱ្យមានតុល្យភាពនៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត និងបន្តមួយរយៈពេល។

**លទ្ធផល:**

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. ពន្យល់អត្ថន័យរបស់គម្រោងគ្រាប់ពូជ និងលក្ខណៈទាំងដប់ដល់មនុស្សម្នាក់ផ្សេងទៀតនៅក្នុងសប្តាហ៍ក្រោយ។

២. ទៅមុខទៀត

ក. ស្គាល់យ៉ាងហោចណាស់របៀបមួយ ដើម្បីបំពេញសេចក្តីត្រូវការមួយនៅក្នុងសហគន៍ ដែលនឹងបង្ហាញចេញសេចក្តីស្រលាញ់ និងព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះអ្នកដែលនៅក្រៅពួកជំនុំ។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីបង្រៀនមនុស្សមួយក្រុមអំពីគម្រោងគ្រាប់ពូជនៅក្នុងខែក្រោយ។

# គ្រាប់ពូជ និងគម្រោងគ្រាប់ពូជ

## គ្រោងមេរៀន

**១. រំឭកមេរៀនឡើងវិញ**

**២. គោលការណ៍អំពីគ្រាប់ពូជសម្រាប់ព័ន្ធកិច្ចពួកជំនុំមូលដ្ឋាន**

ក. **យ៉ូហាន ១២:២៤:** គ្រាប់ពូជធ្លាក់ទៅលើដី ហើយងាប់។

*ឧទាហរណ៍: ផលផ្លែតម្រូវឱ្យមានការលះបង់។*

ខ. **ម៉ាថាយ ១១:៣១-៣២:** រឿងប្រៀបប្រដូចអំពីគ្រាប់ពូជតូចល្អិត។

គ. **យ៉ូហាន ៤:៣៧-៣៨:** ម្នាក់ព្រោះ ម្នាក់ទៀតច្រូត។

ឃ. **១ កូរិនថូស ៦:៣-៩:** ម្នាក់ដាំ ម្នាក់ស្រោចទឹក ព្រះធ្វើឱ្យដុះឡើង។

ង. **២ កូរិនថូស ៩:៦-១៣:** ព្រោះដោយសទ្ធា។

**៣. ធាតុសម្រាប់ការរីកចម្រើនឡើង**

**៤. រូបភាពពន្យល់ផ្ទាល់ខ្លួនអំពីគោលការណ៍គ្រាប់ពូជ**

## ៥. គោលបំណង និងនិយមន័យគម្រោងគ្រាប់ពូជ




ក. **ផលប្រយោជន៍ទាំងបី**

១. ការផ្សាយដំណឹងល្អដែលគ្រប់ជ្រុងជ្រោយ

២. សេរីភាពរួចផុតពីការពឹងផ្អែកលើគេ

៣. បទពិសោធន៍ និងទំនុកចិត្តសម្រាប់សកម្មភាពធំៗជាងនេះ

## ៦. លក្ខណៈរបស់គម្រោងគ្រាប់ពូជ

ក. បណ្តាលចិត្តដោយសារគោលបំណងរបស់ព្រះជាម្ចាស់

ខ. គ្របបាំងនៅក្នុងការអធិស្ឋាន

គ. សាមញ្ញ និងមានរយៈពេលខ្លី

ឃ. រៀបចំផែនការឱ្យបានល្អ

ង. ធនធាននៅក្នុងមូលដ្ឋាន

| **១០ លក្ខណៈ** | |
|---|---|
| ១. បណ្តាលចិត្តដោយសារគោលបំណងរបស់ព្រះជាម្ចាស់<br>២. គ្របបាំងនៅក្នុងការអធិស្ឋាន<br>៣. សាមញ្ញ និងមានរយៈពេលខ្លី<br>៤. រៀបចំផែនការឱ្យបានល្អ<br>៥. ធនធាននៅក្នុងមូលដ្ឋាន | ៦. មិនបោកបញ្ឆោត<br>៧. នៅខាងក្រៅពួកជំនុំ<br>៨. អ្នកដែលទទួលបានផលប្រយោជន៍ចូលរួម<br>៩. មានគោលបំណងគ្រប់ជ្រុងជ្រោយ<br>១០. ព្រះជាម្ចាស់ត្រូវបានលើកតម្កើង |

ច. មិនបោកបញ្ឆោត

ឆ. ធ្វើសម្រាប់អ្នកនៅខាងក្រៅពួកជំនុំ

ជ. អ្នកដែលទទួលបានផលប្រយោជន៍ចូលរួម

ឈ. រៀបចំផែនការដោយមានគោលបំណងឱ្យមានឥទ្ធិពលគ្រប់ជ្រុងជ្រោយ

ញ. ព្រះជាម្ចាស់ត្រូវបានលើកតម្កើង

**៧. ការពង្រឹងឡើងវិញ៖ ប្រយោគណាខ្លះជាឧទាហរណ៍ល្អអំពីគម្រោងគ្រាប់ពូជ ដោយផ្អែកលើលក្ខណៈរបស់គម្រោងគ្រាប់ពូជ? ពន្យល់អំពីមូលហេតុដែលប្រយោគនេះជាឧទាហរណ៍ល្អ ឬមិនល្អ។**

ក. កម្មវិធីលេងកម្សាន្តសម្រាប់ក្មេងនៅក្នុងសហគមន៍ជាការផ្សាយដំណឹងល្អ។

ខ. ដំណើរកម្សាន្តសម្រាប់កុមារដែលស្រេកឃ្លាន ដោយផ្អែកលើការស្ទង់មតិអំពីសេចក្តីត្រូវការរបស់សហគមន៍។

គ. ការជួសជុលបន្ទប់ទឹកនៅផ្ទះរបស់សមាជិកក្រុមជំនុំ។

ឃ. កម្មវិធីអក្ខរកម្មឧបត្ថមដោយរដ្ឋាភិបាល ដែលត្រូវបានគ្របបាំង នៅក្នុងការអធិស្ឋាន។

ង. ការសម្អាតសំរាមនៅថ្ងៃតែមួយដែលលោកអ្នកសម្រេចចិត្តថា នឹងធ្វើ។

ច. សិក្ខាសាលាអំពីជីវជាតិចំណីអាហារ ដែលគណៈកម្មការរៀបចំបម្រើយ៉ាងល្អដែលមានតែអ្នកទៅដល់សហគមន៍ប៉ុណ្ណោះចូលរួម។

ឆ. ផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអំពីគម្រោងគ្រាប់ពូជ ដើម្បីឱ្យសាធារណៈជនដឹងអំពីក្រុមជំនុំ។

ជ. ការបង្កើត និងការបើកដំណើរការទារកដ្ឋាន និងកុមារដ្ឋាន។

ឈ. ការជួបប្រជុំជាមួយសហគមន៍ដើម្បីពិភាក្សាអំពីការបង្កើតកុមារដ្ឋាន ជាលទ្ធផលកើតចេញមកពីការស្វែងរកគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់សហគមន៍។

## ៨. គោលការណ៍បីសម្រាប់ប្រសិទ្ធភាពរយៈពេលវែង

ក. មានតុល្យភាព

ខ. មានការផ្តោតអារម្មណ៍

គ. បន្ត

# គ្រាប់ពូជ និងគម្រោងគ្រាប់ពូជ

## មេរៀន

គ្រាប់ពូជគឺជារូបភាពមួយដែលព្រះយេស៊ូវបានប្រើនៅក្នុងបទគម្ពីរ និងមានការប្រាប់ជាប្រយោលដ៏អស្ចារ្យសម្រាប់ការបម្រើ។ តាមពិតទៅ យើងបានបង្កើតការមួយហៅថា "គម្រោងគ្រាប់ពូជ" ដោយផ្អែកលើគោលការណ៍សំខាន់ពីរដែលយើងបានរៀនចេញពីគ្រាប់ពូជ។

*គោលការណ៍ទី ១: គ្រាប់ពូជមានការប្រាប់ជាប្រយោលយ៉ាងអស្ចារ្យសម្រាប់ការបម្រើ ជាពិសេសនៅពេលដែលគ្រាប់ពូជពន្យល់អំពីការលះបង់។* គោលការណ៍ទីមួយ និងសំខាន់ជាងគេបំផុតអំពីគ្រាប់ពូជបានមកពីការទាយទុករបស់ព្រះយេស៊ូវអំពីការសោយទិវង្គតរបស់ព្រះអង្គ "ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង" (យ៉ូហាន ១២:២៤)។ គ្រាប់ពូជពន្យល់ប្រាប់អំពីការលះបង់។ គ្រាប់ពូជងាប់ដើម្បីសម្រេចគោលបំណងដែលវាត្រូវបានបង្កើតមក គឺបង្កើតផលជាច្រើនឡើង។ គ្រាប់ពូជតូច ប៉ុន្តែនៅពេលដែលគ្រាប់ពូជងាប់ នោះបង្កើតផលបានជាច្រើនឡើង។

ខ្ញុំចូលចិត្តរូបភាពពន្យល់មួយអំពីគោលការណ៍នេះ រូបភាពពន្យល់នោះមកពីប្រទេសឥណ្ឌា ដែលនៅទីនោះខ្ញុំមានអភ័យឯកសិទ្ធិបានបង្រៀនគ្រូគង្វាលមួយក្រុម។ គ្រូគង្វាលម្នាក់មកពីតំបន់ជនបទដាច់ស្រយាល និងក្រីក្រ។ គាត់ និងពួកជំនុំរបស់គាត់រស់នៅជាជនជាតិភាគតិចដែលត្រូវគេសង្កត់សង្កិន។ គាត់ដឹងថា ពួកជំនុំរបស់គាត់ត្រូវបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់សហគមន៍ដែលពួកគេរស់នៅជាមួយ។ ក្រោយពីសិក្ខាសាលារបស់យើងចប់ គាត់បានវិលត្រលប់ទៅផ្ទះវិញ ហើយបានប្រាប់ឱ្យស្ត្រីនៅក្នុងពួកជំនុំរកមើលសេចក្តីត្រូវការនៅក្នុងចំណោមអ្នកជិតខាងរបស់ពួកគេដែលកាន់ព្រហ្មញ្ញសាសនា។ នៅសប្តាហ៍ក្រោយ ពួកស្ត្រីបានប្រាប់ថា អ្នកជិតខាងរបស់ពួកគេភាគច្រើនមានសារី (សម្លៀកបំពាក់) តែមួយសម្រាប់ប៉ុណ្ណោះ។ ដោយព្រោះរដូវនោះក្តៅ ស្ត្រីត្រូវបោកសារីរបស់ខ្លួនជារៀងរាល់ថ្ងៃក្រោយពីធ្វើការយ៉ាងនឿយហត់រួចហើយ។ អ្នកដែលមានសារីតែមួយសម្រាប់ត្រូវនៅក្នុងផ្ទះ ខណៈពេលដែលសារីរបស់គេកំពុងតែហាលថ្ងៃ។ គ្រូគង្វាលបានសួរថា តើមានស្ត្រីប៉ុន្មាននាក់នៅក្នុងពួកជំនុំមានសារីបីសម្រាប់ ហើយព្រមឱ្យមួយសម្រាប់ទៅអ្នកជិតខាងខ្លួនដែលជាអ្នកកាន់ព្រហ្មញ្ញសាសនា។ ម្នាក់ម្តងៗ ស្ត្រីនៅក្នុងពួកជំនុំបានលើកដៃឡើង។ នៅព្រឹកស្អែក ស្ត្រីនៅក្នុងពួកជំនុំបានទៅលេងអ្នកជិតខាងរបស់ពួកគេដែលមានការខ្វះខាត និងបានឱ្យសារីដល់ពួកគេ។ ពួកស្ត្រីដែលជាអ្នកកាន់ព្រហ្មញ្ញសាសនាមានការប៉ះពាល់ចិត្តយ៉ាងខ្លាំង។ ស្ត្រីមួយចំនួនបានសុំឱ្យស្ត្រីដែលជាគ្រីស្ទបរិស័ទអធិស្ឋានដល់ព្រះរបស់ពួកគេសម្រាប់កូនរបស់ខ្លួនដែលមិនទាន់កើតនៅឡើយ។ ការលះបង់នេះបានជះឥទ្ធិពលទៅលើសហគមន៍អ្នកកាន់ព្រហ្មញ្ញសាសនា និងអ្នកនៅក្នុងពួកជំនុំដែលបានយល់ច្បាស់ថា ពួកគេមិនមែនគ្មានអំណាចដូចដែលពួកគេជឿនោះទេ។

ជាញឹកញាប់ ខ្ញុំបានឆ្ងល់ថា តើនឹងមានឥទ្ធិពលខុសប្លែកដែរឬទេ ប្រសិនបើអង្គការគ្រីស្ទបរិស័ទមកកាន់ភូមិនេះ ហើយចែកសម្លៀកបំពាក់ដោយឥតគិតថ្លៃដល់មនុស្សគ្រប់គ្នា? ប្រាកដណាស់ អំណោយច្រើនជាង ហើយអាចបំពេញសេចក្តីត្រូវការខាងសាច់ឈាមបានច្រើនជាង។ ប៉ុន្តែខ្ញុំមានមន្ទិលសង្ស័យថា តើអង្គការនោះនឹងមានឥទ្ធិពលដែលសារីមួយចំនួនតូចរបស់ស្ត្រីនៅក្នុងពួកជំនុំមានដែរឬអត់។ អ្វីដែលបានមកពីស្ត្រីគ្រីស្ទបរិស័ទតំណាងឱ្យការលះបង់ពិតប្រាកដ។ គ្រាប់ពូជបន្តិចបន្តួចមានឥទ្ធិពលយ៉ាងខ្លាំង នៅពេលដែលគ្រាប់ពូជទាំងនោះតំណាងឱ្យការលះបង់។ នៅពេលដែលការបង្ហាញចេញរបស់យើងពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ជាការលះបង់ ខ្ញុំជឿថា នឹងមានឥទ្ធិពលធំជាងការបម្រើរបស់យើងចេញពីភាពហូរហៀរ។ "បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដី..."។ តាមពិតទៅ ខ្ញុំជឿថា ឥទ្ធិពលរបស់ការបម្រើសមាមាត្រទៅនឹងការលះបង់។ លះបង់តិច ឥទ្ធិពលតិច លះបង់ធំ ឥទ្ធិពលធំសម្រាប់នគរព្រះ។

*គោលការណ៍ទី ២: ព្រះជាម្ចាស់គឺជាអ្នកធ្វើឱ្យកើតផល។ យើងស្តាប់បង្គាប់ដាំគ្រាប់ពូជ តែព្រះជាអ្នកធ្វើឱ្យដុះឡើងបង្កើតផល*។ ព្រះយេស៊ូវបានរំលឹកយើងថា យើងមិនអាចទទួលយកកិត្តិយសសម្រាប់ឥទ្ធិពលដែលកើតចេញពីការបម្រើរបស់យើងបានទេ។ "ខ្ញុំបានចាត់អ្នករាល់គ្នាទៅច្រូតចំរូត ដែលមិនបាននឿយនឹងធ្វើសោះ មានអ្នកឯទៀតបាននឿយហត់ ហើយអ្នករាល់គ្នាបានចូលទៅក្នុងការរបស់គេ" (យ៉ូហាន ៤:៣៨)។ ព្រះជាម្ចាស់កំពុងតែធ្វើការរួចទៅហើយនៅក្នុងចិត្តរបស់អ្នកដែលយើងទៅបម្រើ។ នៅពេលណាក៏ដោយដែលមានឥទ្ធិពលសម្រាប់នគរព្រះ ព្រះជាម្ចាស់ជាអ្នកត្រូវទទួលបានព្រះកិត្តិយស មិនមែនយើងទេ។ សាវ័កប៉ុលបានសរសេរថា "ខ្ញុំបានសាបព្រោះ អ័ប៉ុឡូសជាអ្នកស្រោច តែដែលបានដុះឡើងនោះ គឺព្រះបានធ្វើវិញ ហេតុនោះបានជាអ្នកដែលសាបព្រោះ និងអ្នកដែលស្រោច នោះមិនមែនជាអ្វីទេ ស្រេចហើយនឹងព្រះដែលធ្វើឱ្យដុះវិញទេតើ ឯអ្នកដែលសាបព្រោះ និងអ្នកដែលស្រោច នោះដូចគ្នាទេ ហើយក្នុងអ្នកនីមួយៗ នោះនឹងបានរង្វាន់តាមការដែលខ្លួនធ្វើ" (១ កូរិនថូស ៣:៦-៨)។ ការបម្រើរបស់យើងមានគោលបំណងពង្រីករាជ្យរបស់ព្រះគ្រីស្ទ គឺឱ្យបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅផែនដី ដូចជានៅស្ថានសួគ៌ដែរ។ គោលដៅគឺជាការពង្រីកនគរព្រះ មិនមែនជាតួរលេខអំពីការរីកចម្រើនឡើងនៃពួកជំនុំទេ។

ដោយផ្អែកលើគោលការណ៍ទាំងនេះ យើងបានរកឃើញរបៀបមួយ ដើម្បីបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់នៅក្នុងសហគមន៍ គឺជាគម្រោងគ្រាប់ពូជ។ គម្រោងគ្រាប់ពូជគឺជាគម្រោងតូចៗ ដែលពួកជំនុំលះបង់ប្រើធនធាននៅក្នុងមូលដ្ឋាន ដើម្បីបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្ទ។ គម្រោងគ្រាប់ពូជធ្វើឡើងដោយក្រុមតូចៗនៅក្នុងពួកជំនុំមាន គ្រួសារ ការប្រកបគ្នានៅផ្ទះ ក្រុមតូច ថ្នាក់សិក្សាព្រះគម្ពីរ និងថ្នាក់រៀនសាលាថ្ងៃអាទិត្យ (ការបង្ហាញចេញតាមរបៀបតូចៗពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ពេលដែលបុគ្គលគឺជាអ្នកធ្វើត្រូវបានហៅថា វិន័យខាងឯសេចក្តីស្រលាញ់ ហើយយើងពិភាក្សានៅក្នុងមេរៀនមួយផ្សេងទៀត)។

ខ្ញុំអាចនិយាយប្រាប់រឿងមួយហើយមួយទៀតអំពីរបៀបដែលព្រះជាម្ចាស់បានប្រទានពរដល់ការលះបង់ស្តាប់បង្គាប់របស់ពួកជំនុំមូលដ្ឋាន នៅពេលដែលពួកគេបានធ្វើគម្រោងគ្រាប់ពូជ! ប្រាកដណាស់ សូមមើលគេហទំព័ររបស់

យើង www.harvestfoundation.org ដើម្បីមើលឃើញរឿងរ៉ាវរបស់អំពីគម្រោងគ្រាប់ពូជមកពីគ្រប់ទីកន្លែងនៅជុំវិញពិភពលោក ។

## គោលបំណងរបស់គម្រោងគ្រាប់ពូជ




១. ដើម្បីប្រើឧបករណ៍ដែលសាមញ្ញ និងដែលបានបង្ហាញថាមានប្រសិទ្ធភាព ដើម្បីជួយក្រុមជំនុំមូលដ្ឋានចាប់ផ្តើមបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់មនុស្សដែលនៅក្រៅរូបកាយរបស់ព្រះគ្រីស្ទ ។

២. ជួយឱ្យក្រុមជំនុំអាចធ្វើជាអ្នកប្រកាសដំណឹងល្អតាមរយៈការប្រព្រឹត្តិ ។

## និយមន័យ

គម្រោងគ្រាប់ពូជគឺជាព័ន្ធកិច្ចតូច និងមានរយៈពេលខ្លី របស់អ្នកជឿ ។ គម្រោងធ្វើឡើងដោយប្រើធនធានក្នុងមូលដ្ឋាន ដើម្បីបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់អ្នកដែលនៅខាងក្រៅសហគមន៍អ្នកជឿ ។ និយមន័យនេះអាចពន្យល់បានតាមរយៈដ្យាក្រាមដូចតទៅនេះ ។

## ផលប្រយោជន៍របស់គម្រោងគ្រាប់ពូជ




មានផលប្រយោជន៍ជាច្រើនកើតចេញពីគម្រោងគ្រាប់ពូជ ប៉ុន្តែយ៉ាងហោចណាស់ មានផលប្រយោជន៍បីដែលបាចលេចធ្លោជាផលប្រយោជន៍ដែលសំខាន់ជាងគេបំផុតនៅក្នុងការធ្វើគម្រោងគ្រាប់ពូជរបស់យើងរយៈពេលម្ភៃឆ្នាំមកនេះ ។

១. ការផ្សាយដំណឹងល្អដែលគ្រប់ជ្រុងជ្រោយៈ គម្រោងគ្រាប់ពូជជួយពួកជំនុំដែលអនុវត្តគម្រោងនេះឱ្យអាចមើលឃើញអំណាចរបស់

ការបង្ហាញចេញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់តាមរបៀបដែលសាមញ្ញ និងខ្ជាប់ខ្ជួន នៅក្នុងការទាញមនុស្សមកក្នុងនគរព្រះ។

ពួកជំនុំអ័រតូដុក និងពួកជំនុំដំណឹងល្អជាច្រើនមានបទពិសោធន៍ជាមួយការផ្សាយដំណឹងល្អ តាមរយៈការប្រកាស។ បញ្ហាមួយក្នុងចំណោមបញ្ហារបស់ការផ្សាយដំណឹងល្អតាមរយៈការប្រកាសគឺថា ជាញឹកញាប់ ការប្រកាសបែបនេះកាត់ផ្ដាច់ចេញពីបទពិសោធន៍ជាមួយនឹងសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់។ គំរូនៅក្នុងព្រះគម្ពីរគឺរស់នៅតាមរបៀបមួយដែលធ្វើឱ្យអ្នកដែលមានទំនាក់ទំនងជាមួយយើង មើលឃើញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ បន្ទាប់មកបើកចិត្តទទួលយកខ្លឹមសារដំណឹងល្អដែលបានប្រកាស។

២. <u>សេរីភាពរួចផុតពីការពឹងផ្អែកលើគេ:</u> ពួកជំនុំជាច្រើនដែលយើងបានមានអភ័យឯកសិទ្ធិធ្វើការជាមួយចាប់តាំងពីដើមឆ្នាំ ១៩៨០ គឺជាពួកជំនុំធម្មតានៅក្នុងប្រទេសតតិយលោក។ ជាញឹកញាប់ ពួកគេមិនមែនជាអ្នកមានទេ។ ការយល់ឃើញរបស់ពួកគេអំពីព័ន្ធកិច្ចបម្រើសេចក្ដីត្រូវការខាងសាច់ឈាម និងខាងសង្គម គឺត្រូវពឹងផ្អែកលើគម្រោងធំៗ ដោយមានលុយមកពីខាងក្រៅសហគមន៍។ គម្រោងគ្រាប់ពូជជួយពួកជំនុំទាំងនេះឱ្យមើលឃើញថា ព្រះជាម្ចាស់ប្រើសកម្មភាពតូចៗដែលប្រើធនធានក្នុងមូលដ្ឋានតាមរបៀបយ៉ាងអស្ចារ្យ និងយូរអង្វែង។

៣. <u>បទពិសោធន៍ និងទំនុកចិត្តសម្រាប់សកម្មភាពធំៗជាងនេះ:</u> ក្រោយពីធ្វើគម្រោងគ្រាប់ពូជជាច្រើនទៅ យើងបានភ្ញាក់ផ្អើលនឹងរបៀបដែលសកម្មភាពតូចៗដែលប្រើធនធានក្នុងមូលដ្ឋានទាំងនេះបានកសាងបទពិសោធន៍ និងទំនុកចិត្តសម្រាប់សកម្មភាពធំៗជាងនេះ។

**លក្ខណៈរបស់គម្រោងគ្រាប់ពូជ:** អស់រយៈពេលជាច្រើនឆ្នាំមកហើយ យើងបានវាយតម្លៃធាតុដែលធ្វើឱ្យគម្រោងគ្រាប់ពូជមានប្រសិទ្ធភាព។ មានលក្ខណៈចំនួនដប់ដែលហាក់បីដូចជាពាក់ព័ន្ធនឹងការសម្រេចបានការធ្វើទីបន្ទាល់បែបគ្រប់ជ្រុងជ្រោយនេះនៅក្នុងសហគមន៍។ លក្ខណៈទាំងនេះគឺជាសេចក្ដីណែនាំដ៏មានតម្លៃនៅក្នុងការរៀបចំផែនការ និងការអនុវត្តន៏គម្រោងគ្រាប់ពូជ (លក្ខណៈទាំងនេះមិនមែនជាច្បាប់តឹងរ៉ឹងទេ ប៉ុន្តែគួរតែមាននៅក្នុងគម្រោងគ្រាប់ពូជភាគច្រើន)។ នៅពេលដែលយើងបណ្ដុះបណ្ដាលអ្នកដឹកនាំពួកជំនុំអំពីការរៀបចំផែនការគម្រោងគ្រាប់ពូជ យើងបានសុំឱ្យមើលថា គម្រោងរបស់ពួកគេដែល

| **១០ លក្ខណៈ** | |
|---|---|
| ១. បណ្ដាលចិត្តដោយសារគោលបំណងរបស់ព្រះជាម្ចាស់<br>២. គ្របបាំងនៅក្នុងការអធិស្ឋាន<br>៣. សាមញ្ញ និងមានរយៈពេលខ្លី<br>៤. រៀបចំផែនការឱ្យបានល្អ<br>៥. ធនធាននៅក្នុងមូលដ្ឋាន | ៦. មិនបោកបញ្ឆោត<br>៧. នៅខាងក្រៅពួកជំនុំ<br>៨. អ្នកដែលទទួលបានផលប្រយោជន៏ចូលរួម<br>៩. មានគោលបំណងគ្រប់ជ្រុងជ្រោយ<br>១០. ព្រះជាម្ចាស់ត្រូវបានលើកតម្កើង |

បានរៀបចំផែនការរួចហើយឆ្លុះបញ្ចាំងឱ្យឃើញការណែនាំនិមួយៗនេះ ហើយសម្រាប់ករណីដែលមិនមាន នោះត្រូវតែមានហេតុផលឱ្យបានល្អ។

១. គម្រោងគ្រាប់ពូជត្រូវបានបណ្តាលចិត្តដោយសារគោលបំណងរបស់ព្រះជាម្ចាស់។ ជាញឹកញាប់ គ្រីស្ទបរិស័ទប្រហែលជាជាប់នៅក្នុងអន្ទាក់ធ្វើការល្អដែលបណ្តាលចិត្តដោយសារចិត្តអាណិតអាសូររបស់មនុស្ស ធ្វើតាមកំឡាំងមនុស្ស។ ពីមុនមក គម្រោងត្រូវបានធ្វើឡើង ពេលដែលបានឃើញសេចក្តីត្រូវការ មានអារម្មណ៏ថាជាសេចក្តីត្រូវការ អ្នកនៅក្នុងមូលដ្ឋានបង្ហាញប្រាប់ រកឃើញនៅក្នុងការស្ទង់មតិ ឬនៅពេលដែលមានធនធានខាងក្រៅដើម្បីបំពេញសេចក្តីត្រូវការនោះ។ ព័ន្ធកិច្ចគ្រីស្ទបរិស័ទគួរតែខុសប្លែកពីនេះ។ គ្រីស្ទបរិស័ទគួរតែជាអ្នកដែលមានចិត្តអាណិតអាសូរ ប៉ុន្តែការបណ្តាលចិត្តខ្លាំងជាងគេបំផុតរបស់យើងគួរតែជាបំណងប្រាថ្នាចង់ឆ្លុះបញ្ចាំងឱ្យឃើញគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់មនុស្ស ដែលលើសពីចិត្តអាណិតអាសូររបស់មនុស្សចំពោះសេចក្តីត្រូវការទៅទៀត។ គម្រោងគ្រាប់ពូជគួរតែត្រូវបានជ្រើសរើសតាមរយៈការស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺតាមរយៈការអធិស្ឋាន ការសិក្សាបទគម្ពីរ និងការស្គាល់សហគមន៍ច្បាស់។

បទពិសោធន៍ដំបូងមួយរបស់យើងគឺជាមួយភូមិក្រីក្រដាច់ស្រយាលមួយនៅក្នុងប្រទេសមិកស៊ិកូភាគកណ្តាល មានសេចក្តីត្រូវការយ៉ាងច្រើនលើសលប់នៅក្នុងភូមិនោះ។ ពួកចាស់ទុំនៅក្នុងភូមិនោះបានប្រែចិត្តជឿទាំងក្រុម។ ពួកគេបានចំណាយពេលទៅតំបន់ភ្នំ ដើម្បីអធិស្ឋាន និងតមរយៈពេលបីថ្ងៃ សូមឱ្យព្រះអម្ចាស់ប្រាប់ពួកគេពីកិច្ចការទីមួយដែលពួកគេត្រូវធ្វើ ក្នុងនាមជាអ្នកជឿថ្មីលើព្រះយេស៊ូវ។ នៅពេលដែលពួកគេសិក្សាបទគម្ពីរដោយយកចិត្តទុកដាក់ និងអធិស្ឋាន ពួកគេជឿថា ព្រះជាម្ចាស់កំពុងតែប្រាប់ពួកគេឱ្យធ្វើកិច្ចការមួយដែលប្រឆាំងនឹងវប្បធម៌ទាំងស្រុង គឺសង់ផ្ទះសម្រាប់ស្ត្រីមេម៉ាយប្រាំពីរនាក់នៅក្នុងភូមិរបស់ពួកគេ។ ពួកគេបានធ្វើកិច្ចការនោះ។ នៅពេលដែលព័ត៌មានអំពីសកម្មភាពនេះផ្សព្វផ្សាយចេញទៅក្នុងតំបន់ទាំងមូល មានការផុសផុលបានកើតឡើង! អ្នកមានជំនាញនៅក្នុងការអភិវឌ្ឍន៍ប្រាកដជាធ្វើការខាងផ្នែកអនាម័យ ទឹកស្អាត សុខភាព ការអប់រំ ឬការបង្កើតការងារ។ ប៉ុន្តែ ព្រះជាម្ចាស់ដឹងអ្វីដែលបង្ហាញចេញច្បាស់ពីសេចក្តីស្រលាញ់របស់ព្រះអង្គចំពោះមនុស្ស។ ពួកចាស់ទុំទាំងនោះបានឆ្លើយតប ដោយលះបង់ស្តាប់បង្គាប់តាមអ្វីដែលពួកគេជឿថា ពួកគេបានឮមកពីព្រះជាម្ចាស់ ហើយនគររបស់ព្រះជាម្ចាស់ត្រូវបានពង្រីក។

២. គម្រោងគ្រាប់ពូជគួរតែត្រូវបានគ្របបាំងនៅក្នុងការអធិស្ឋាន។ តាមរយៈការអធិស្ឋាន គម្រោងគ្រាប់ពូជត្រូវបានព្រះវិញ្ញាណបរិសុទ្ធប្រាប់ ដឹកនាំ និងប្រទានអំណាចឱ្យអាចធ្វើបាន។ គម្រោងនេះគួរតែធ្វើឡើង ជាការឆ្លើយតបទៅនឹងបញ្ញត្តិរបស់ព្រះយេស៊ូវ។ គម្រោងនេះត្រូវតែធ្វើឡើងដោយនៅក្នុងអំណាចព្រះចេស្តានៃព្រះ

វិញ្ញាណរបស់ព្រះគ្រីស្ទ ហើយយើងបានទទួលអំណាចនោះ នៅពេលដែលយើងផ្តួចផ្តើម និងធ្វើការបម្រើចេញពីការស្តាប់បង្គាប់ ដោយផ្សាភ្ជាប់នឹងការអធិស្ឋាន។

៣. គម្រោងគ្រាប់ពូជត្រូវតែសាមញ្ញ និងមានរយៈពេលខ្លី ព្រមទាំងតូច និងមិនស្មុគស្មាញ។ គម្រោងគួរតែប្រើពេលវេលាមិនលើសពីពីរថ្ងៃ ទោះបីជាការរៀបចំផែនការ និងការត្រៀមរៀបចំប្រហែលជាចំណាយពេលយូរជាងនេះក៏ដោយ។ គម្រោងតូចៗមានផលប្រយោជន៍ពិសេសៈ (ក) បទគម្ពីរបង្ហាញថា ព្រះជាម្ចាស់លើកតម្កើង និងចម្រើនកាងារដែលតូច ហើយស្មោះត្រង់ (ខ) មនុស្សរីកចម្រើនឡើងខាងជំនឿ និងលទ្ធភាព នៅពេលដែលពួកគេប៉ុនប៉ង និងសម្រេចបានគម្រោងតូចៗ។ គម្រោងតូចៗអនុញ្ញាតឱ្យមនុស្សបរាជ័យ រៀន និងបម្រើម្តងទៀត ដោយមិនមានផលវិបាកធំទេ (គ) រួមគ្នាមក គម្រោងតូចៗអាចមានឥទ្ធិពលយ៉ាងធំធេងមកលើសហគមន៍ (ឃ) គម្រោងតូចៗផ្តល់បទពិសោធន៍សម្រាប់សកម្មភាពធំៗជាងនេះ។

៤. គម្រោងគ្រាប់ពូជគួរតែត្រូវបានរៀបចំផែនការឱ្យបានល្អ។ នៅពេលដែលព្រះយេស៊ូវមានបន្ទូលអំពី "ការគិតអំពីការបង់ថ្លៃ" ព្រះអង្គបានយោងទៅរកការរៀបចំផែនការជាសកម្មភាពធម្មតាសម្រាប់គម្រោងដែលជោគជ័យ។ ដំណាក់កាលនៅក្នុងការរៀបចំផែនការរួមមានការត្រៀមរៀបចំ ការអធិស្ឋាន ការកត់ត្រា ការអនុវត្តន៍ និងការវាយតម្លៃ។ ឧបករណ៍ ការរៀបចំផែនការ នេះត្រូវបានលើកឡើងនៅក្នុងមេរៀនមួយដាច់ដោយឡែក គឺការរៀបចំផែនការគម្រោងគ្រាប់ពូជ និងការធ្វើរបាយការណ៍។

៥. គម្រោងគ្រាប់ពូជត្រូវធ្វើដោយប្រើធនធាននៅក្នុងមូលដ្ឋាន។ ផែនការអភិវឌ្ឍជាច្រើនសម្រាប់គម្រោងដែលអាចបញ្ចប់បាន ទាល់តែមានធនធានខាងក្រៅ។ ធនធានខាងក្រៅអាចមានប្រយោជន៍ ប៉ុន្តែពេលវេលា និងលក្ខខណ្ឌសម្រាប់ផ្តល់ធនធាននោះគឺជាគន្លឹះ។ ប្រសិនបើពួកជំនុំមូលដ្ឋានមិនបានរៀនលះបង់វិនិយោគធនធានរបស់ខ្លួននៅក្នុងព័ន្ធកិច្ច មុនពេលដែលប្រើធនធានខាងក្រៅទេ នោះកាន់តែនាំឱ្យពួកជំនុំមូលដ្ឋានគិតថាខ្លួនគ្មានអំណាច ហើយកាន់តែធ្វើឱ្យការផ្តួចផ្តើមនៅក្នុងមូលដ្ឋានកាន់តែពិបាកថែមទៀតនៅពេលអនាគត។ ធនធានខាងក្រៅត្រូវបានប្រើយ៉ាងល្អបំផុត ទៅតាមលក្ខខណ្ឌដូចតទៅនេះ (ក) អ្នកនៅក្នុងមូលដ្ឋានបានបង្ហាញចេញឆន្ទៈព្រមលះបង់ប្រើធនធានផ្ទាល់ខ្លួនរបស់គេ (ខ) ធនធានខាងក្រៅមិនមែនសម្រាប់ជំនួសធនធាននៅក្នុងមូលដ្ឋានទេ (គ) ធនធានខាងក្រៅធ្វើឱ្យធនធាននៅក្នុងមូលដ្ឋានរីកចម្រើនឡើងតាមលក្ខណៈគុណ មិនមែនតាមលក្ខណៈបូកទេ (ឃ) មនុស្សយល់ថា តាមពិតទៅ ព្រះជាម្ចាស់ជាអ្នកប្រទានធនធាន។

៦. គម្រោងគ្រាប់ពូជមិនបោកបញ្ឆោត។ គម្រោងទាំងនេះគួរតែឆ្លុះបញ្ចាំងឱ្យឃើញពីព្រះហឫទ័យអាណិតអាសូររបស់ព្រះជាម្ចាស់ចំពោះភាពបាក់បែក។ គម្រោងទាំងនេះមិនមែនជាវិធីដើម្បីបង្ខំមនុស្សឱ្យប្រែចិត្តជឿទេ។ គម្រោងគ្រាប់ពូជផ្តល់ឱ្យយើងនូវឱកាស ដើម្បីស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះយេស៊ូវឱ្យស្រលាញ់អ្នកជិតខាងរបស់ខ្លួនដោយគ្មានលក្ខខណ្ឌ ទោះបីជាមានការឆ្លើយតបមកវិញបែបណាក៏ដោយ។ ប្រាកដណាស់ យើង

ពិតជាចង់ឃើញមនុស្សបាត់បង់មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូវ និងមើលឃើញពួកជំនុំរីកចម្រើនឡើង។ ប៉ុន្តែប្រសិនបើការប្រែចិត្តជឿ និងពួកជំនុំរីកចម្រើនឡើងគឺជាបំណងចិត្តចម្បងសម្រាប់ការស្តាប់បង្គាប់របស់យើង នោះការខិតខំប្រឹងប្រែងរបស់យើងទៅជាបោកបញ្ឆោត។ ព្រះយេស៊ូវមិនដែលបោកបញ្ឆោតមនុស្សទេ។ ព្រះអង្គបានប្រោសពួកគេឱ្យជាសះស្បើយ ពីព្រោះការបំពេញសេចក្ដីត្រូវការខាងសាច់ឈាមបានលើកតម្កើង និងឆ្លុះបញ្ចាំងឱ្យឃើញពីព្រះហឫទ័យរបស់ព្រះវរបិតាព្រះអង្គ។ អ្នកខ្លះដែលព្រះអង្គបានប្រោសឱ្យជា បានឆ្លើយតបដោយទទួលស្គាល់ព្រះអង្គជាព្រះអម្ចាស់ ហើយអ្នកខ្លះទៀតមិនបានទទួលស្គាល់ទេ ប៉ុន្តែព្រះយេស៊ូវមិនបានផ្អាកព័ន្ធកិច្ចឡើយ ទោះបីជានៅពេលដែលព្រះអង្គដឹងថា នឹងគ្មានការឆ្លើយតបខាងវិញ្ញាណក៏ដោយ។ ព្រះយេស៊ូវបានដឹងថា មានតែមនុស្សឃ្លង់ម្នាក់ប៉ុណ្ណោះក្នុងចំណោមមនុស្សឃ្លង់ទាំងដប់នាក់ដែលនឹងឆ្លើយតប ប៉ុន្តែព្រះអង្គបានប្រោសទាំងដប់នាក់ឱ្យបានជាសះស្បើយ។

៧. គម្រោងគ្រាប់ពូជមានទិសដៅតម្រង់ទៅរកអ្នកនៅក្រៅពួកជំនុំ។ ការបម្រើដល់សេចក្ដីត្រូវការរបស់អ្នកនៅក្នុងពួកជំនុំល្អ ហើយចាំបាច់ ប៉ុន្តែគម្រោងគ្រាប់ពូជត្រូវបានបង្កើតឡើងដើម្បីជួយពួកជំនុំបង្ហាញចេញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ដល់អ្នក*នៅក្រៅ*ពួកជំនុំ។ យើងគឺជាអំបិល និងជាពន្លឺនៅក្នុងលោកិយ មិនត្រឹមតែនៅក្នុងពួកជំនុំប៉ុណ្ណោះទេ។ យើងបម្រើសមាជិកសហគមន៍ ពីព្រោះយើងស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះយេស៊ូវឱ្យស្រលាញ់អ្នកជិតខាងដូចខ្លួនឯង។

៨. អ្នកដែលទទួលបានផលប្រយោជន៍ពីគម្រោងគ្រាប់ពូជគួរតែចូលរួមផងដែរនៅក្នុងគម្រោង ប្រសិនបើអាចធ្វើកើត។ នៅពេលដែលអ្នកកំពុងត្រូវបានជួយ ចូលរួមនៅក្នុងដំណើរការរៀបចំផែនការ និងការជួយ ពួកគេមានកិត្តិយសចូលរួមនៅក្នុងការប្រោសពួកគេឱ្យជា។ ការធ្វើកិច្ចការសម្រាប់មនុស្សដែលមានសមត្ថភាពចូលរួម ប៉ុន្តែមិនបានចូលរួម គឺជាបិតុនិយម។ តាមពិតទៅ យើងលេលាខ្លាំងណាស់ ប្រសិនបើយើងមិនប្រើចំណេះដឹង និងការយកចិត្តទុកដាក់របស់ពួកគេអំពីបញ្ហា។ មនុស្សដែលបានទទួលផលប្រយោជន៍ និងចូលរួមនៅក្នុងគម្រោងព័ន្ធកិច្ច មានអារម្មណ៍ថាជាម្ចាស់ខ្លាំងជាង គឺពួកគេទំនងជាប្រើ ថែរក្សា និងអភិវឌ្ឍគម្រោងឱ្យកាន់តែប្រសើរឡើង។

៩. គ្រប់គម្រោងគ្រាប់ពូជនឹងមានផ្នែកចម្បងដែលទទួលរងឥទ្ធិពល ប៉ុន្តែគម្រោងគ្រាប់ពូជត្រូវមានគោលបំណងគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលផែនការសម្រាប់ឥទ្ធិពលនៅក្នុងផ្នែកនិមួយៗ។ នៅពេលដែលគម្រោងគ្រាប់ពូជមានលក្ខណៈខាងសង្គម ឬខាងសាច់ឈាម នោះយន្តការធ្វើសកម្មភាពមានភាពតានតឹងយ៉ាងខ្លាំង ធ្វើឱ្យភ្លេចសង្កត់ធ្ងន់លើខាងវិញ្ញាណ និងខាងផ្នែកដទៃទៀតដោយអចេតនា។ នៅក្នុងផែនការគម្រោងគ្រាប់ពូជនិមួយៗ វាជាការសំខាន់ណាស់ដែលត្រូវសួរថាតើគួរតែដាក់បញ្ចូលផ្នែកទទួលរងឥទ្ធិពលនិមួយៗដែរឬអត់ និងដាក់នៅកន្លែងណា បន្ទាប់មកសរសេរដាក់ចូលក្នុងផែនការទាំងមូល។

១០. គម្រោងគ្រាប់ពូជគួរតែថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ដូច្នេះព្រះជាម្ចាស់ត្រូវបានលើកតម្កើង ។ ដូចដែលការរៀបចំផែនការល្អិតល្អន់មានសារៈសំខាន់ជាយ៉ាងណា ការវាយតម្លៃដោយល្អិតល្អន់មានសារៈសំខាន់ជាយ៉ាងនោះដែរ ប៉ុន្តែវាយតម្លៃតាមបទដ្ឋាននគរព្រះ ។ ឧបករណ៍វាយតម្លៃត្រូវបានលើកឡើងនៅក្នុងមេរៀនមួយផ្សេងទៀត គឺការរៀបចំផែនការគម្រោងគ្រាប់ពូជ និងការធ្វើរបាយការណ៍ ។ បទដ្ឋានចម្បងសម្រាប់ការវាយតម្លៃគឺថា នរណាទទួលបានកិត្តិយស ។ តើជាអ្នកដែលធ្វើគម្រោង ឬព្រះជាម្ចាស់? អ្នកដែលទទួលបានកិត្តិយសគួរតែជាអ្នកដែលត្រាស់ហៅយើងឱ្យស្រលាញ់អ្នកជិតខាងរបស់យើង គឺព្រះជាម្ចាស់ ។

**គោលការណ៍ទាំងបីសម្រាប់ប្រសិទ្ធភាពរយៈពេលយូរ:** ការធ្វើគម្រោងគ្រាប់ពូជមួយដាច់តែឯងគឺជាវិធីយ៉ាងល្អ ដើម្បីចាប់ផ្តើមបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះដល់ពិភពលោកដែលបាក់បែក ។ ទោះបីយ៉ាងណាក៏ដោយ គោលការណ៍ទាំងបីនេះនឹងជួយផ្តល់ឥទ្ធិពលខ្លាំងបំផុតនៅក្នុងសហគមន៍មួយ ។

> **គោលការណ៍ទាំងបីសម្រាប់ប្រសិទ្ធភាពរយៈពេលយូរ**
>
> - មានតុល្យភាព: ព័ន្ធកិច្ចនៅក្នុងគ្រប់ផ្នែកទាំងអស់ ។
> - មានការផ្តោតអារម្មណ៍: ព័ន្ធកិច្ចដែលមានតុល្យភាពបម្រើដល់សហគមន៍ដដែល ។
> - បន្ត: របៀបរស់នៅបម្រើព័ន្ធកិច្ចម្តងហើយម្តងទៀតមួរយៈពេល ។

១. គម្រោងគ្រាប់ពូជត្រូវតែមានតុល្យភាព: គម្រោងគ្រាប់ពូជគួរតែត្រូវបានបង្កើតឡើងដើម្បីបង្ហាញចេញព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះគ្រប់ផ្នែកទាំងអស់ដែលមានសេចក្តីត្រូវការ ។ គំរូដែលយើងប្រើសម្រាប់ការបម្រើគឺ លូកា ២:៥២ ។ ប្រភេទទាំងបួននៅក្នុងលូកា ២:៥២ មាន ប្រាជ្ញា ខាងសាច់ឈាម ខាងវិញ្ញាណ និងខាងសង្គម ។ ឧទាហរណ៍ សមាជិកពួកជំនុំនៅក្រុងការ៉ាពីតា ប្រទេសវេនេហ្ស៊ូអេឡា បានរៀបចំរចនាសម្ព័ន្ធគម្រោងគ្រាប់ពូជ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញប្រភេទទាំងឡាយដែលមាននៅក្នុងលូកា ២:៥២ ។

- ប្រាជ្ញា: សមាជិកពួកជំនុំបានបង្រៀនអំពីការការពារពីគ្រឿងញៀននៅសាលារដ្ឋ ។ ពួកគេត្រូវបានអញ្ជើញឱ្យត្រលប់មកវិញ ដើម្បីបង្រៀនថែមទៀត ។
- ខាងសាច់ឈាម: សមាជិកពួកជំនុំ ២៥ នាក់បានចូលរួមជាមួយអ្នកនៅក្នុងសហគមន៍នៅក្នុងការជួសជុលបង្គន់ ប្រព័ន្ធភ្លើង តុទូ ប្រព័ន្ធបង្ហូរទឹកកខ្វក់សម្រាប់សាលារដ្ឋ ។
- ខាងវិញ្ញាណ: ពួកជំនុំបានរៀបចំពិធីសាស្ត្រជាច្រើនសម្រាប់ការផ្សាយដំណឹងល្អនៅក្នុងសហគមន៍ ។
- ខាងសង្គម: ពួកជំនុំបានជួសជុលតារាងបាល់បោះ ហើយបានរៀបចំឱ្យមានការលេងបាល់បោះ និងការប្រកួត ។ សកម្មភាពនេះបានប្រោសព្យាបាលការបែកបាក់រវាងយុវជនពីរក្រុម ។

២. គម្រោងគ្រាប់ពូជគួរតែមានការផ្តោតអារម្មណ៍៖ មនុស្សដដែលត្រូវតែមើលឃើញព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះពួកគេនៅក្នុងគ្រប់ផ្នែកទាំងអស់។ ពួកជំនុំមូលដ្ឋានដែលធ្វើព័ន្ធកិច្ចដោយមានការផ្តោតអារម្មណ៍នឹងមិនបំពេញសេចក្តីត្រូវការខាងសាច់ឈាមនៅក្នុងសហគមន៍មួយ សេចក្តីត្រូវការខាងសង្គមនៅក្នុងសហគមន៍ទីពីរ សេចក្តីត្រូវការខាងវិញ្ញាណនៅក្នុងសហគមន៍ទីបី និងសេចក្តីត្រូវការខាងប្រាជ្ញានៅក្នុងព្រះគម្ពីរនៅក្នុងសហគមន៍ទីបួនទេ។ ពួកជំនុំនឹងបម្រើដោយមានតុល្យភាព ប៉ុន្តែអ្នកដែលទទួលបានផលប្រយោជន៍ពីព័ន្ធកិច្ចរបស់ពួកជំនុំមើលឃើញព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់តែមួយផ្នែកប៉ុណ្ណោះ។ ព័ន្ធកិច្ចដែលមានការផ្តោតអារម្មណ៍បង្ហាញចេញព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះសេចក្តីត្រូវការប្រភេទនិមួយៗដល់មនុស្សដដែល។

៣. គម្រោងគ្រាប់ពូជគួរតែមានលក្ខណៈបន្ត គឺជារបៀបរស់នៅបម្រើព័ន្ធកិច្ច៖ ការបង្ហាញចេញសេចក្តីស្រលាញ់មិនគួរកើតឡើងតែមួយដង ឬពីរដងនៅក្នុងមួយឆ្នាំទេ។ សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់គួរតែជាផ្នែកមួយរបស់ព័ន្ធកិច្ចដែលនៅតែបន្តសម្រាប់គ្រីស្ទបរិស័ទម្នាក់ៗ និងសម្រាប់ពួកជំនុំមួយរយៈពេល។

យើងបានឃើញការផ្សារភ្ជាប់គ្នាយ៉ាងសំខាន់រវាងគោលគំនិតទាំងនេះ និងព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយដែលមានប្រសិទ្ធភាព។ ប៉ុន្តែ ទោះបីជាសេចក្តីណែនាំទាំងអស់ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវក៏ដោយ គម្រោងគ្រាប់ពូជនឹងមិនពង្រីកនគររបស់ព្រះជាម្ចាស់ទេ ប្រសិនបើមិនមានព្រះវិញ្ញាណបរិសុទ្ធដឹកនាំ និងប្រទានអំណាចឱ្យនោះ។ ចូរស្វែងរកការដឹកនាំរបស់ព្រះអង្គ! សូមឱ្យរាជ្យទ្រង់បានមកដល់ សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅក្នុងសហគមន៍ដែលពួកជំនុំមូលដ្ឋានរបស់លោកអ្នកស្ថិតនៅ។

*y Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ 85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត៖ លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១០០០ ច្បាប់។*

**ធនធានល្អដែលបានផ្តល់ជាយោបល់ជូនៈ**

Disciple Nations Alliance website: www.disciplenations.org/resource/course. Section: Wholistic Ministry.